United Nations Human Rights

OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia

# មតិយោបល់លើបទបញ្ញត្តិមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

**ខែឧសភា ឆ្នាំ២០១៤**

មតិយោបល់ខាងក្រោមនេះ ត្រូវបានរៀបរៀងតាក់តែងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងគោលបំណងដើម្បីជួយជ្រោមជ្រែងដល់ដំណើរការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ចាប់ពីពេលនេះទៅហៅថាសេចក្តីព្រាងច្បាប់)។ មតិយោបល់ទាំងនេះ មានមូលដ្ឋានជាបឋមផ្អែកលើកាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់កម្ពុជា ក៏ដូចជាលិខិតុបករណ៍អន្តរជាតិ និងលិខិតុបករណ៍តំបន់នានាដែលពាក់ព័ន្ធស្តីពីឯករាជភាពតុលាការ។

មតិយោបល់ទាំងនេះ ដាក់ជូនចំពោះបទបញ្ញត្តិនៃសេចក្តីព្រាងច្បាប់ថ្មីបំផុត ដូចត្រូវបានពិភាក្សានៅចំពោះមុខរដ្ឋសភា។ មតិយោបល់ទាំងនេះក៏ផ្តោតផងដែរលើវិស័យផ្សេងៗ ដែលការិយាល័យ OHCHR ជឿជាក់ថា គួរត្រូវដាក់បញ្ចូលក្នុងច្បាប់នេះ។ ការិយាល័យយើងខ្ញុំជឿថា ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា អាចតំណាងឲ្យជំហានដ៏សំខាន់ និងវិជ្ជមានមួយ សំដៅដល់ការពង្រឹងឯករាជភាពតុលាការកម្ពុជា។ ឯករាជភាពតុលាការ គឺជាបុរេតម្រូវការចំពោះនីតិរដ្ឋ ហើយក៏ជាកិច្ចធានាការពារជាមូលដ្ឋាន ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[1]

*ដើម្បីជាប្រយោជន៍ដល់ការបង្កើតនូវការអនុវត្តល្អៗ ការិយាល័យឧត្តមស្នងការសូមផ្តល់អនុសាសន៍ថា គួរតែរៀបចំឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈមួយ ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ។ នៅក្នុងន័យនេះ ការិយាល័យឧត្តមស្នងការ ត្រៀមខ្លួនជាស្រេច ដើម្បីផ្តល់ជាជំនួយក្នុងការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈបែបនេះ។ លើសពីនេះ ការិយាល័យឧត្តមស្នងការ ត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការបង្ហាញជូនដល់សមាជិករដ្ឋសភា និងព្រឹទ្ធសភា អំពីការវិភាគរបស់ខ្លួនទៅលើច្បាប់នេះតាមទស្សនៈវិស័យនៃកាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់កម្ពុជា។*

[1] See the Bangalore Principles of Judicial Conduct, available at http://www.unrol.org/doc.aspx?d=2328

## ១/- គោលការណ៍ទូទៅ

គោលបំណងចំបងនៃច្បាប់នេះ គួរតែផ្តល់នូវមូលដ្ឋានផ្លូវច្បាប់ច្បាស់លាស់មួយដល់ឯករាជ្យភាពតុលាការ។ នៅក្នុងន័យនេះ ច្បាប់នេះ គួរការពារ និងលើកស្ទួយនូវគោលការណ៍នានាដូចខាងក្រោមនេះ៖

- គោលការណ៍ឯករាជ្យភាពនៃតុលាការ និងចៅក្រម
- គោលការណ៍នៃការបែងចែកអំណាច (នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)
- គោលការណ៍អនាគតិរបស់ចៅក្រម

គោលការណ៍ជាមូលដ្ឋានទាំងនេះ ត្រូវបានតំកល់ទុកក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ (ICCPR) ដែលប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីក្នុងឆ្នាំ១៩៩២។ យោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ICCPR គឺជាផ្នែកមួយនៃច្បាប់កម្ពុជា។

បទបញ្ញត្តិនៃ ICCPR ដែលពាក់ព័ន្ធបំផុត គឺមាត្រា១៤ ដែលការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ បទបញ្ញត្តិនេះរួមមានសិទ្ធិទទួលបានសវនាការជាសាធារណៈដោយ "សាលាជំរះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់" ។ គណៈកម្មាធិការសិទ្ធិមនុស្សដែលជាស្ថាប័នឃ្លាំមើលអន្តរជាតិបង្កើតឡើងដោយ ICCPR បានអនុម័តសេចក្តីពន្យល់ទូទៅលេខ៣២ អំពីមាត្រា១៤ ដែលចែងពីការណែនាំលំអិតដល់រដ្ឋភាគីពីរបៀបបកស្រាយមាត្រា១៤។[2] ក្នុងឯកសារនេះ គណៈកម្មាធិការសិទ្ធិមនុស្សបានរំលឹកថា តុលាការគួរតែឯករាជ្យពីស្ថាប័ននីតិប្រតិបត្តិ និងនីតិបញ្ញត្តិរបស់រដ្ឋាភិបាល។[3]

គោលការណ៍ទាំងឡាយបានលើកឡើងខាងលើ ក៏រាប់បញ្ចូលផងដែរក្នុងគោលការណ៍ជាមូលដ្ឋានរបស់សហប្រជាជាតិស្តីពីឯករាជ្យនៃប្រព័ន្ធតុលាការ និងគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះ រាជអាជ្ញា។[4] គោលការណ៍ទាំងនេះចែងយ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់ជំពូកស្តីពីប្រព័ន្ធតុលាការ។

*នៅក្នុងន័យនេះ ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ឲ្យដាក់បញ្ចូលឡើងវិញទៅក្នុងមាត្រា១ នូវការយោងដល់គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពតុលាការ ដូចមានចែងនៅក្នុងសំណៅដំបូងនៃសេចក្តីព្រាងច្បាប់នេះ។ បន្ថែមពីនេះ ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ថា ច្បាប់នេះក៏យោងផងដែរដល់គោល*

[2] See full text of General Comment No.32 on Article 14 at http://cambodia.ohchr.org/EN/PagesFiles/PublicationsIndex.htm
[3] See General Comment No.32 on Article 14, para.18.
[4] Both documents are available at http://cambodia.ohchr.org/EN/PagesFiles/PublicationsIndex.htm

*ការណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា និងរួមបញ្ចូលនូវកិច្ចធានាការពារជាក់លាក់ក្នុងការការពារគោលការណ៍ឯករាជ្យភាពចៅក្រម និងព្រះរាជអាជ្ញា មានដូចជា៖*

> *ឯករាជ្យភាពតុលាការត្រូវធានាការពារដោយរដ្ឋធម្មនុញ្ញ។ នេះជាករណីយកិច្ចរបស់យើងទាំងអស់គ្នា ក្នុងការគោរព និងប្រតិបត្តិតាមឯករាជ្យភាពតុលាការ។*
>
> *មិនត្រូវមានការជ្រៀតជ្រែកដោយមិនសមស្រប ឬគ្មានហេតុផលណាមួយឡើយ នៅក្នុងនីតិវិធីតុលាការ ហើយសេចក្តីសម្រេចរបស់តុលាការ ក៏មិនត្រូវស្ថិតក្រោមការពិនិត្យឡើងវិញនោះដែរ។ គោលការណ៍នេះ មិនបានធ្វើឲ្យខូចខាតដល់ការពិនិត្យឡើងវិញតាមផ្លូវតុលាការ ឬការបន្ធូរបន្ថយ ឬការសម្រាលទោសដែលធ្វើឡើង ដោយអាជ្ញាធរមានសមត្ថកិច្ចនៃការផ្តន្ទាទោសផ្តល់ដោយតុលាការ ស្របតាមច្បាប់នោះទេ។*[5]

## ២/- ឯករាជ្យភាពតុលាការ

ក្នុងមាត្រា៦ មិនមានការកំណត់ច្បាស់លាស់ពីការធានាសន្តិសុខដល់ចៅក្រម និងព្រះរាជអាជ្ញា ក៏ដូចជាសមាជិកគ្រួសាររបស់ពួកគេ ថាតើត្រូវធានាយ៉ាងដូចម្តេច និងដោយអ្នកណា។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ឲ្យតាក់តែងមាត្រានេះបានកាន់តែច្បាស់ជាងនេះ - ជាឧទាហរណ៍ អាចចែងថា៖*

> *អាជ្ញាធរត្រូវការពារដល់បូរណភាពរូបកាយរបស់ចៅក្រម ព្រះរាជអាជ្ញានិងសមាជិកក្រុមគ្រួសាររបស់ពួកគេ នៅពេលណាសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ ត្រូវបានគំរាមកំហែង ដោយសារតែការបំពេញតួនាទីកាត់ក្តីរបស់ខ្លួន។*[6]

មាត្រា៧ ចែងថា ចៅក្រម និងព្រះរាជអាជ្ញាខ្លះ អាចបំពេញការងារនៅក្រសួងយុត្តិធម៌ ក្នុងរយៈពេលជាក់លាក់ណាមួយបាន ដោយសារថានេះគឺជាការអនុវត្តជាក់ស្តែងសព្វថ្ងៃនេះ។ បញ្ញត្តិនេះពុំបានបញ្ជាក់ថាតាមលក្ខខ័ណ្ឌ និងកាលៈទេសៈណា ដែលចៅក្រមអាចបំពេញការងារនៅក្រសួងយុត្តិធម៌នោះទេ។ ក្នុងករណីណាក៏ដោយ តាមស្មារតីនៃគោលការណ៍ការបែងចែកអំណាចរវាងនីតិប្រតិបត្តិ និងអំណាចតុលាការ វាមិនសមស្របទាល់តែសោះ សំរាប់សមាជិកនៃអំណាចតុលាការ ធ្វើការឲ្យអំណាចនីតិប្រតិបត្តិ នៅឯក្រសួងយុត្តិធម៌។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ឲ្យដកមាត្រា៧នេះចេញ។*

---

[5] See principles 1 to 6.

[6] See Guidelines on the Role of Prosecutors, para.5.

មាត្រា៩ និយាយពីការផ្លាស់ប្តូរចៅក្រម និងព្រះរាជអាជ្ញា។ ធ្លាប់មានការចោទប្រកាន់ក្នុងអតីតកាលពីការផ្លាស់ប្តូរចៅក្រមឲ្យទៅកាន់ខេត្តឆ្ងាយ ថាជាទម្រង់នៃការដាក់ទណ្ឌកម្ម។ ដោយមិនប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការចោទប្រកាន់នេះ ច្បាប់ត្រូវការពារចៅក្រម ប្រឆាំងនឹងហានិភ័យនៃការសំរេចផ្ទេរបែបនេះ ដោយគ្មានមូលដ្ឋានផ្លូវច្បាប់ត្រឹមត្រូវ។ ក្នុងករណីដែលចៅក្រមម្នាក់បានប្រព្រឹត្តយ៉ាងជាក់ស្តែងនូវកំហុសវិន័យខ្លះ គាត់មិនគួរត្រូវបានផ្លាស់ទៅតុលាការមួយទៀតទុកជាការដាក់វិន័យនោះទេ - មានទណ្ឌកម្មសមស្របផ្សេងទៀតជាច្រើនដូចមានចែងក្នុងមាត្រា៥៥ ដែលនឹងធ្វើឲ្យកាន់តែប្រសើរដល់ប្រសិទ្ធផល និងសុចរិតភាពរបស់តុលាការដែលស្ថិតនៅខេត្តឆ្ងាយៗ។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ឲ្យដកប្រយោគទី២ នៃមាត្រា៩ចេញ។*

មាត្រា៥០ កថាខ័ណ្ឌទី៣ និងមាត្រា៩៦ កថាខ័ណ្ឌទី៤ តម្រូវឲ្យមានការបំភ្លឺខ្លះ។ ចៅក្រម និងព្រះរាជអាជ្ញា ត្រូវតែមិនលំអៀង ហើយត្រូវតែធ្វើឲ្យគេឃើញថាមិនលំអៀង។ ដូចអ្នកដទៃទៀតដែរ ទោះជាចៅក្រម និងព្រះរាជអាជ្ញា ជាការពិតណាស់ អាចជាសមាជិកនៃសមាគមណាមួយបានដោយសេរី តែពួកគាត់មិនគួរភ្ជាប់ខ្លួនយ៉ាងជិតដិតទៅនឹងគណបក្សនយោបាយណាមួយទេ។ ប្រការនេះនឹងអនុគ្រោះដល់ភាពអព្យាក្រិតដែលត្រូវបានមើលឃើញរបស់ពួកគាត់ ក្រោមក្រសៃភ្នែករបស់សាធារណជន។

បទប្បញ្ញត្តិជាក់លាក់មួយហាមឃាត់ពីការចូលជា*សមាជិកសកម្ម*នៃគណបក្សនយោបាយមួយ នឹងជួយពង្រឹងដល់គោលការណ៍ឯករាជ្យភាព និងអនាគតិរបស់តុលាការ។ ការដាក់បញ្ចូលនូវបទប្បញ្ញត្តិបែបនេះ គឺជាអនុសាសន៍ជាក់លាក់មួយរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុងរបាយការណ៍របស់លោកស្តីពីប្រព័ន្ធតុលាការ។[7]

*ហេតុដូច្នេះ ការិយាល័យឧត្តមស្នងការសូមផ្តល់អនុសាសន៍ថា មាត្រា៥០និងមាត្រា៩៦ ចែងឲ្យបានជាក់ច្បាស់ថា ចៅក្រម និងព្រះរាជអាជ្ញា មិនគួរជា<u>សមាជិកសកម្ម</u>នៃគណបក្សនយោបាយមួយនោះទេ។*

*បន្ថែមពីនេះ ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ច្បាប់នេះត្រូវចែងថា៖ ចៅក្រម ត្រូវដកខ្លួនពីរាល់ទម្រង់នៃសកម្មភាពគណបក្សនយោបាយ និងពីការចូលរួមប្រមូលផ្តុំនយោបាយ ឬព្រឹត្តិការណ៍រៃអង្គាសថវិកាគណបក្សនយោបាយ ឬការផ្តល់វិភាគទានដល់គណបក្សនយោបាយ តាមវិធីណាក៏ដោយ ធ្វើឲ្យគេមើលឃើញ*

[7] A/HRC/15/46, para.67.

*ថាយើងជាមនុស្សរបស់គណបក្សនយោបាយមួយ ឬគាំទ្រជាសាធារណៈដល់គណបក្សនយោបាយមួយនោះ។ ចៅក្រម ត្រូវចងចាំថា សកម្មភាពនយោបាយរបស់សមាជិកក្រុមគ្រួសារជិតដិតណាម្នាក់ ក៏អាចជាកង្វល់អំពីអព្យាក្រឹត្យភាពរបស់ខ្លួននៅក្នុងរឿងក្តីណាមួយ។*[8]

មាត្រា១០៨ ចែងថា ចៅក្រម ឬព្រះរាជអាជ្ញាដែលមិនបំរើការងារក្នុងរយៈពេលណាមួយត្រូវជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រសិនបើគាត់ចង់ប្រកបការងារអ្វីផ្សេងពីនេះ។ ប្រសិនបើមានប្រព័ន្ធជូនដំណឹងណាមួយនៅក្នុងករណីបែបនេះមែន ការជូនដំណឹងបែបនេះ គួរធ្វើទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

*ប្រសិនបើនៅតែរក្សាទុកមាត្រា១០៨ ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ឲ្យដាក់ជំនួស "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌" ដោយ "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" នៅក្នុងមាត្រានេះវិញ។*

## ៣/- សេរីភាពនៃការបញ្ចេញមតិ និងការបង្កើតសមាគម

ចៅក្រម និងព្រះរាជអាជ្ញា ក៏ដូចជាពលរដ្ឋដទៃទៀតដែរ មានសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ដូចត្រូវបានធានាការពារតាមមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ (ICCPR) ដែលប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីក្នុងឆ្នាំ១៩៩២។ គោលការណ៍នេះ ត្រូវបានបញ្ជាក់ជាថ្មីនៅក្នុងគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពតុលាការ (កថាខ័ណ្ឌទី៨) ដែលបានរំលឹកជាពិសេសថា៖

> ព្រះរាជអាជ្ញាមានសិទ្ធិចូលរួមចំណែកក្នុងការពិភាក្សាជាសាធារណៈ នូវរាល់បញ្ហាដែលទាក់ទងនឹងច្បាប់ ការគ្រប់គ្រងយុត្តិធម៌ និងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ព្រមទាំងចូលរួម ឬបង្កើតអង្គការនៅមូលដ្ឋាន អង្គការជាតិ ឬអង្គការអន្តរជាតិ និងចូលរួមប្រជុំរបស់អង្គការទាំងនេះ ដោយគ្មានទទួលរងនូវការបាត់បង់ផលប្រយោជន៍ខាងវិជ្ជាជីវៈ ដោយសារតែមូលហេតុនៃសកម្មភាពស្របច្បាប់របស់ខ្លួន ឬដោយសារតែសមាជិកភាពរបស់ខ្លួន នៅក្នុងអង្គការស្របច្បាប់ទាំងនេះទេ។

សិទ្ធិនេះ គឺមិនមែនគ្មានដែនកំណត់នោះទេ ហើយ "ចៅក្រមគួរតែប្រកាន់ខ្ជាប់ជានិច្ច នូវឥរិយាបថមួយ ដើម្បីរក្សាសេចក្តីថ្លៃថ្នូររបស់តុលាការ ព្រមទាំងអនាគតិ និងឯករាជ្យភាពរបស់តុលាការ។[9]

[8] See Guide to judicial conduct of the UK Supreme Court, para.3.3, available at http://www.supremecourt.uk/about/judicial-conduct-and-complaints.html

[9] See Basic Principles on the Independence of the Judiciary (para.8).

មាត្រា៩៣ នៃសេចក្តីព្រាងច្បាប់នេះ តំរូវឲ្យមានការស្នើសុំនូវការអនុញ្ញាតជាមុនពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មុននឹងចៅក្រម ចង់និយាយ ឬសរសេរអ្វីដែលទាក់ទងនឹងការងាររបស់ខ្លួន។ មាត្រា៩៦ ក៏មានចែងពីលក្ខខណ្ឌតម្រូវប្រហាក់ប្រហែលគ្នានេះដែរ សំរាប់ព្រះរាជអាជ្ញា ត្រូវសុំការអនុញ្ញាតជាមុនពីក្រសួងយុត្តិធម៌។ នេះគឺជាការរិតត្បិតមួយដែលមិនសមរម្យ លើសេរីភាពនៃការបញ្ចេញមតិ។ ជាការពិតហើយ ចៅក្រម និងព្រះរាជអាជ្ញាមិនគួរអធិប្បាយ លើរឿងក្តីដែលខ្លួនកំពុងតែចាត់ការនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើ ជាឧទាហរណ៍ ចៅក្រម ចង់ផ្តល់បទសម្ភាសន៍ ឬក៏ផ្តល់ការបង្ហាញអំពីតួនាទីរបស់ចៅក្រមជាទូទៅ ពួកគេមិនគួរត្រូវស្នើសុំការអនុញ្ញាតជាមុននោះទេ។ ចៅក្រម គួរតែត្រូវបានអនុញ្ញាតអោយចូលរួម ក្នុងការជជែកពិភាក្សាជាទូទៅ អំពីប្រព័ន្ធយុត្តិធម៌។

ក្នុងករណីនេះ សៀវភៅមគ្គុទេសន៍ អំពីក្រមសីលធម៌វិជ្ជាជីវៈ ចេញដោយតុលាការកំពូលចក្រភពអង់គ្លេស រំលឹកថា៖

> វាមានសារៈសំខាន់ដល់សមាជិកតុលាការកំពូល ផ្តល់បទបង្ហាញ ឬធ្វើបាវកថា ចូលរួមក្នុងសន្និសីទ និងសិក្ខាសាលា សរសេរនិងបង្រៀន ហើយជាទូទៅចូលរួមចំណែកដល់ការពិភាក្សាអំពីបញ្ហាប្រយោជន៍សាធារណៈនៅក្នុងច្បាប់ ការគ្រប់គ្រងយុត្តិធម៌ និងវិស័យតុលាការ។ គោលដៅរបស់ពួកគាត់ គឺចង់លើកកំពស់ការយល់ដឹងវិជ្ជាជីវៈ និងជាសាធារណៈនៃបញ្ហាដែលបានចោទឡើង និងអំពីតួនាទីរបស់តុលាការ។[10]

***ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ លុបចោលនៅក្នុងមាត្រា៩៣ និងមាត្រា៩៦ នូវលក្ខខណ្ឌតំរូវឲ្យចៅក្រម និងព្រះរាជអាជ្ញា ត្រូវសុំការអនុញ្ញាតជាមុន មុននឹងខ្លួនអាចនិយាយជាសាធារណៈអំពីបញ្ហានានាទាក់ទងនឹងការងាររបស់គេ។***

ចៅក្រម និងព្រះរាជអាជ្ញា ក៏ដូចជាពលរដ្ឋដទៃទៀតដែរ មានសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមតាមមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦។ សិទ្ធិនេះ ត្រូវបានបញ្ជាក់ជាថ្មី នៅក្នុងគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ (កថាខ័ណ្ឌទី៩) និងគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា (កថាខ័ណ្ឌទី៩)។ សិទ្ធិនេះក៏ត្រូវបានចែងផងដែរ នៅក្នុងលិខិតតុបករណ៍ថ្នាក់តំបន់ ដូចជាសេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងនៃគោលការណ៍ស្តីពីឯករាជ្យភាពតុលាការ នៅក្នុងព្រឹត្តិប័ត្រ តំបន់ច្បាប់អាស៊ី (កថាខ័ណ្ឌទី៩)។[11] សេចក្តីព្រាងច្បាប់នេះ មិនមានចែងណាមួយអំពីសិទ្ធិនេះទេ។

---

[10] Para.3.4.

[11] Available at http://lawasia.asn.au/beijing-statement.htm

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ឲ្យដាក់បញ្ចូលបទប្បញ្ញត្តិមួយ ដោយគូសបញ្ជាក់ឡើងវិញពីសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញា មានសេរីភាពក្នុងការចូលរួម/បង្កើតសមាគម។ សេចក្តីព្រាងច្បាប់នេះ គួរចែងថា៖*

*ចៅក្រម និងព្រះរាជអាជ្ញា ត្រូវមានសិទ្ធិបង្កើត និងចូលរួមសមាគមវិជ្ជាជីវៈ ឬអង្គការដទៃទៀត ដើម្បីតំណាងឲ្យផលប្រយោជន៍របស់ខ្លួន លើកស្ទួយការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួន និងដើម្បីការពារឯករាជ្យភាពតុលាការ។*

## ៤/- លក្ខណៈសម្បត្តិ ការជ្រើសរើស និងការបណ្តុះបណ្តាល

គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពតុលាការ ចែងថា "បុគ្គលដែលត្រូវបានជ្រើសឲ្យបំរើការក្នុងតុលាការ ត្រូវតែជាបុគ្គលសុចរិត ទៀងត្រង់ និងមានសមត្ថភាព ដោយមានការបណ្តុះបណ្តាលត្រឹមត្រូវ ឬមានលក្ខណៈសម្បត្តិតាមផ្លូវច្បាប់"។[12]

មាត្រា១៩ ចែងពីបញ្ជីនៃល័ក្ខខ័ណ្ឌតម្រូវសំរាប់ការជ្រើសរើសសិស្សចៅក្រម - លក្ខខណ្ឌតំរូវឲ្យមាន "កាយសម្បទាគ្រប់គ្រាន់ ដើម្បីបំពេញការងារ" មិនគួរត្រូវបានបកស្រាយតាមលក្ខណៈណាក៏ដោយ ដែលនឹងផាត់ចោលជនពិការឡើយ។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ថា លក្ខខណ្ឌតម្រូវនៅក្នុងមាត្រា ១៩ មិនគួរត្រូវបានបកស្រាយតាមលក្ខណៈណាក៏ដោយ ដែលនឹងផាត់ចោលជនពិការនោះទេ។*

## ៥/- លក្ខខណ្ឌការងារ និងមុខតំណែង

មាត្រា១៦ មានចែងពីការឈប់សំរាកមាតុភាពសំរាប់ចៅក្រមជាស្ត្រី ដែលជាចំនុចមួយ គួរឲ្យស្វាគមន៍។ ក្នុងន័យសមភាពយេនឌ័រ ចៅក្រមបុរស ក៏គួរមានសិទ្ធិឈប់សំរាកបិតុភាពដែរ ដើម្បីជួយមើលថែទារក និងម្តាយដែលទើបសំរាលរួច។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ឲ្យដាក់បញ្ចូលទៅក្នុងមាត្រា១៦ នូវបទប្បញ្ញត្តិ ដែលចែងថា ចៅក្រមបុរសមានសិទ្ធិឈប់សំរាកបិតុភាព។*

យោងតាមគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពតុលាការ ប្រព័ន្ធនៃការតំលើងឋានន្តរសក្តិចៅក្រមគួរតែផ្អែកលើ "កត្តា*សន្ទានុម័ត* ជាពិសេសសមត្ថភាព សុចរិតភាពនិងបទពិសោធន៍។[13]

[12] Para.10.
[13] Para.13.

គោលការណ៍ណែនាំស្តីពីតួនាទីព្រះរាជអាជ្ញា ក៏មានបទប្បញ្ញត្តិប្រហាក់ប្រហែលគ្នានេះដែរ។[14] កត្តាមួយទៀត គួរតែនិយាយយោងដល់ដែរនោះគឺ ធម្មនុញ្ញសហគមន៍អឺរ៉ុបស្តីពីលក្ខន្តិកៈចៅក្រម ដែលមានចែងនូវពីរប្រព័ន្ធនៃការតំលើងឋានន្តរសក្តិ៍ គឺមួយផ្អែកលើអតីតភាពការងារ និងមួយទៀតផ្អែកលើគុណូបការៈ។ ទាក់ទងទៅនឹងគុណូបការៈ ធម្មនុញ្ញនេះ ចែងថា ប្រព័ន្ធនេះគួរតែៈ

> "ផ្អែកទាំងស្រុងលើគុណសម្បត្តិ និងគុណូបការៈដែលបានប្រតិបត្តិនៅក្នុងការបំពេញតួនាទីរបស់ខ្លួន ដែលផ្តល់ដល់ចៅក្រម តាមមធ្យោបាយនៃការវាយតំលៃជាក់ស្តែងលើចៅក្រមម្នាក់ៗ ឬច្រើននាក់ និងបានពិភាក្សាជាមួយចៅក្រមសាម៉ី។ បន្ទាប់មក សេចក្តីសម្រេចអំពីការតំលើងឋានន្តរសក្តិ៍ ត្រូវបានប្រកាសដោយអាជ្ញាធរមួយឯករាជ្យពីអំណាចនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ដែលអាជ្ញាធរនេះ មានសមាជិកយ៉ាងហោចណាស់ពាក់កណ្តាលជាចៅក្រមដែលត្រូវបានជ្រើសតាំងដោយសហការីជាចៅក្រមរបស់គាត់ ឬតាមសំណើរបស់អាជ្ញាធរនេះ ឬមានការឯកភាពពីអាជ្ញាធរនេះ។ ចៅក្រមដែលមិនត្រូវបានស្នើសុំឲ្យមានការតំលើងឋានន្តរសក្តិ៍ ត្រូវមានសិទ្ធិប្តឹងទៅអាជ្ញាធរនេះ។"[15]

នៅក្នុងសេចក្តីព្រាងនេះ មាត្រា២៨ ធ្វើបញ្ជីមួយចំនួននៃលក្ខណៈសម្បត្តិសំរាប់ការតំលើងឋានន្តរសក្តិ៍ ដែលរួមមានទាំង "ការសម្រេចភារកិច្ចបានល្អ"។ អនុលោមតាមមាត្រា៣១ ការបំពេញតួនាទីរបស់ចៅក្រមម្នាក់ៗ ត្រូវតែទទួលបានការវាយតំលៃជារៀងរាល់ឆ្នាំ ដោយចៅក្រមដែលមានឋានន្តរសក្តិ៍ខ្ពស់ជាង តាមរយៈការបំពេញតាមចំណុចសំណួរទាំងឡាយ។ ប្រព័ន្ធស្រដៀងគ្នា នៃការវាយតំលៃលើការបំពេញតួនាទីនេះ ក៏មានចែងសំរាប់ព្រះរាជអាជ្ញាទាំងអស់ដែរ (ជំពូក៣ ផ្នែកទី៧)។ ខ្លឹមសារនៃចំណុចសំណួរទាំងនេះ ដែលនឹងសន្មត់ថាត្រូវប្រើសំរាប់ធ្វើសេចក្តីសម្រេច អំពីការតំលើងឋានន្តរសក្តិ៍ នឹងក្លាយទៅជាបញ្ហាយ៉ាងសំខាន់។ ចំណុចសំណួរទាំងនេះ គួរត្រូវបានតាក់តែងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងទូលាយជាមួយចៅក្រមព្រះរាជអាជ្ញានិងអ្នកពាក់ព័ន្ធទាំងអស់ ឧទា.មេធាវី។ មាត្រា៣៣ ចែងពិស្តារពីសមាសភាពនៃគណៈកម្មាធិការតំលើងឋានន្តរសក្តិ៍។ ដើម្បីការពារឯករាជភាពតុលាការ អំណាចនីតិប្រតិបត្តិមិនគួរជាប់ពាក់ព័ន្ធនឹងបញ្ហានានាដែលទាក់ទងនឹង In order to protect the independence of the judiciary, the executive should not be involved in issues related to the promotion of judges and prosecutors. Consequently, the Secretary of state of MoJ should not be the Chairperson of this Commission. In any case, there might be no need for such a Commission which does not include any elected judge or prosecutor. Decisions on promotions should be referred to the SCM instead.

---

[14] Para.7. See also Beijing Statement of Principles on the Independence of the Judiciary in the LAWASIA Region (para.17).

[15] Para.4.1.

OHCHR recommends that the Law explicitly state that promotion criteria are exclusively based on objective criteria, in particular ability, integrity and experience. Any performance evaluation system should be elaborated in consultation with judges, prosecutors and other relevant stakeholders. The body deciding on promotions, whether it is the SCM or another body, should not include any member of the executive. Consequently, OHCHR recommends amending Article 33 to give responsibility to the SCM to decide on promotion.

According to the Basic Principles on the Independence of the Judiciary, judges shall have guaranteed tenure "until a mandatory retirement age or the expiry of their term of office, where such exists".[16] Article 62 of the draft Law sets the retirement age at 60 for all judges. Nonetheless, the draft Law introduces a different regime for judges of the Supreme Court. These judges continue to work beyond the age of 60 and retire "at the request of the concerned judge". The provision even seems to suggest that judges of the Supreme Court could work beyond the age of 65 if authorised by the SCM upon their request. It is unclear whether this means that if authorised by the SCM, some Supreme Court judges could continue to work well beyond the age of retirement set by the law and for an indefinite period.

OHCHR recommends that judges of the Supreme Court continue to serve beyond the age of 60 *only* if expressly authorised by the SCM to do so. The Law should set an upper age limit beyond which no judge should be allowed to continue to serve.

## ៦/- វិន័យ ការព្យួរការងារ និងការដកចេញពីមុខតំណែង

កំហុសវិន័យ គួរត្រូវបានកំណត់ក្នុងន័យមួយជាក់លាក់ដោយច្បាប់។[17] ជាប្រការគួរតែត្រូវរំលឹកឡើងវិញថា ចៅក្រម ឬព្រះរាជអាជ្ញា គួរត្រូវបានព្យួរការងារ ឬដកចេញពីមុខតំណែង "សំរាប់តែហេតុផលអសមត្ថភាព ឬឥរិយាបទដែលរារាំងគាត់មិនឲ្យបំពេញការងាររបស់គាត់បាន"។[18]

សេចក្តីព្រាងច្បាប់នេះ មានជំពូកមួយស្តីពីទណ្ឌកម្មវិន័យ (មាត្រា៥៤ ដល់មាត្រា៥៦)។[19] មាត្រា៥៤ កំនត់អំពីកំហុសវិន័យទូទៅពេក (ដូចជា កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ ការធ្វើអោយប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រម

---

[16] Para.12.
[17] See Guidelines on the Role of Prosecutors (para.21).
[18] See Basic Principles on the Independence of the Judiciary (para.18).
[19] Disciplinary proceedings are covered in the draft Law on the SCM.

សីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា)។ កំហុសទាំងនេះ ត្រូវតែកំណត់ន័យឲ្យបានច្បាស់លាស់ជាងនេះ នៅក្នុងច្បាប់នេះ ឬនៅក្នុងច្បាប់ដោយឡែកមួយទៀត។ មាត្រា៥៥ កំណត់ទណ្ឌកម្មវិន័យមាន២ប្រភេទ។ ទោះជាយ៉ាងណាក៏ដោយ គ្មានការចង្អុលបង្ហាញ អំពីប្រភេទនៃទណ្ឌកម្មណាមួយគួរយកមកអនុវត្តចំពោះកំហុសវិន័យបែបណាមួយនោះទេ។

មាត្រា៥៥ ចែងពី "ការផ្លាស់ប្តូរដោយបង្ខំ តំរូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម" - ចំនុចនេះមានន័យពុំច្បាស់លាស់។ ស្របតាមមតិយោបល់របស់ការិយាល័យយើងខ្ញុំ ដែលផ្តល់ជូនលើមាត្រា៩ អំពីការផ្លាស់ប្តូរទៅតុលាការមួយផ្សេងទៀត ប៉ុន្តែគឺត្រូវទៅសាលាបណ្តុះបណ្តាលមួយ ដូចជារាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការជាដើម។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ថា កំហុសវិន័យ គួរតែកំនត់ន័យដោយមានសំអាងច្បាស់លាស់ ចំពោះការរំលោភបំពានធ្ងន់ធ្ងរដល់ក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា។ ការិយាល័យឧត្តមស្នងការ ក៏សូមផ្តល់អនុសាសន៍ផងដែរ ឲ្យគូសបញ្ជាក់អំពីប្រភេទនៃទណ្ឌកម្មវិន័យមួយណា ដែលនឹងត្រូវយកមកអនុវត្តចំពោះកំហុសវិន័យណាមួយ។*

## ៧/- តួនាទី និងកាតព្វកិច្ចរាយការណ៍របស់ព្រះរាជអាជ្ញា

មាត្រា៧៤ ចែងអំពីតួនាទីរបស់ព្រះរាជអាជ្ញា។ ទោះបីជាតួនាទីចំបងរបស់ព្រះរាជអាជ្ញា គឺធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ ក៏ព្រះរាជអាជ្ញា ត្រូវទទួលខុសត្រូវផងដែរក្នុងការគ្រប់គ្រងលើការអនុវត្តសេចក្តីសំរេចរបស់តុលាការ ត្រួតពិនិត្យការឃុំខ្លួន និងមន្ត្រីនគរបាលយុត្តិធម៌ ដូចមានចែងយ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញា គួរដឹកនាំការសម្របសម្រួលជាមួយនគរបាល តុលាការ មេធាវី ស្មាគ្គីសាធារណៈ និងជាមួយក្រសួង ឬស្ថាប័នផ្សេងៗរបស់រាជរដ្ឋាភិបាល។[20]

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ ឲ្យដាក់បញ្ចូលនូវការទទួលខុសត្រូវទាំងនេះ របស់ព្រះរាជអាជ្ញា ទៅក្នុងមាត្រា៧៤។*

មាត្រា៧៦ ចែងថា ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍និងតុលាការកំពូល គួររាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាពការងាររបស់ខ្លួន។ យន្តការរាយការណ៍បែបនេះ គួរជួយដល់ការបង្កើនគណនេយ្យភាព និងតម្លាភាពថែមទៀត នៅក្នុងប្រព័ន្ធយុត្តិធម៌។ ដើម្បីធ្វើឲ្យយន្តការរាយការណ៍នេះ កាន់តែមានន័យ ព្រះរាជអាជ្ញាគួរត្រូវបានស្នើសុំឲ្យរាយការណ៍អំពីសកម្មការងារផ្សេង

[20] See Guidelines on the Role of Prosecutors (para.20).

ទៀត ដូចជាចំនួនរឿងក្តីដែលបានចោទប្រកាន់ ចំនួនរឿងក្តីដែលតម្កល់ទុកឥតចាត់ការ ការប្រជុំទៀងទាត់រវាងមន្ត្រីនគរបាលយុត្តិធម៌ តុលាការ និងពន្ធនាគារ និងការឯកភាពលើយោបល់ដែលបានធ្វើឡើងពីកិច្ចប្រជុំនេះ ការចុះពិនិត្យពន្ធនាគារ និងការចុះទៅពិនិត្យប៉ុស្តិ៍ប៉ូលីសអំឡុងពេលធ្វើរបាយការណ៍នេះ។ ដើម្បីជួយដល់ព្រះរាជអាជ្ញា គួរតែមានរូបមន្តសរសេររបាយការណ៍មួយ រឹតតែប្រសើរ។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ថា គួរតែមានគោលការណ៍ណែនាំបន្ថែមទៀត អំពីយន្តការសរសេររបាយការណ៍ចែងនៅក្នុងច្បាប់បន្ទាប់ និងដែលនៅពេលនោះនឹងមានការតាក់តែងរូបមន្តសរសេររបាយការណ៍។ ការិយាល័យឧត្តមស្នងការ ត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់ជំនួយសំរាប់បញ្ហានេះ។*

រៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា
ភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤